ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

១០-០១-២០០៧ -ព្រះរាជក្រម នស/រកម/០១០៧/០០១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីមូលបត្ររដ្ឋ ៨០១

២_ព្រះរាជក្រឹត្យ

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៩ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងបរិស្ថាន ៨១៣

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៤០ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ៨២៦

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៤១ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៨២៨

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៧-០១-២០០៧ -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្តីពីការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៨៣១

១៧-០១-២០០៧ -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៣២

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៣៣

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៨៣៤

១៨-០១-២០០៧ -អនុក្រឹត្យលេខ៥០ អនក្រ.តតស្តីពីការផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨៣៥

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៣៦

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៣៧

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៨

១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៣៩
១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០
១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤២
១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៨៤៣
១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤៤
១៨-០១-២០០៧ -អនុក្រឹត្យលេខ ៥៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤៥
១៩-០១-២០០៧ -អនុក្រឹត្យលេខ ៦០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៤៦
១៩-០១-២០០៧ -អនុក្រឹត្យលេខ ៦១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៤៧
១៩-០១-២០០៧ -អនុក្រឹត្យលេខ ៦២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៨៤៩
២២-០១-២០០៧ -អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៥០
២២-០១-២០០៧ -អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៥៦
២៣-០១-២០០៧ -អនុក្រឹត្យលេខ ៦៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៥៧

III-ភាគរបស់បណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-១២-២០០៦ -ប្រកាសលេខ ១៤០៣ សហវ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យថវិកាខេត្ត-ក្រុង ៨៦៨

២- ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១១-០១-២០០៧ -សេចក្តីសំរេចលេខ ០០៩ សសរ/គ.ជ.វ.វ ស្តីពីការបង្កើតក្រុមគាំទ្រកម្មវិធី ដែលផ្ទេរពីកម្មវិធីសិលា មកក្រោមការគ្រប់គ្រងរបស់ គ.ជ.វ.វ ៩២៣

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៤៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយ ឈរ៉ា ខនស្រ្តាក់សិន** ៩២៧
១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៤៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃីង អេស៊ា ត្រេឌីង** ៩២៩
១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហោ យាន អ៊ិនវេសមេន ខូ អិលធីឌី** ៩៣១

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ធី អឌូ អេន ត្រាក់ធំរ** ៩៣៣

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីខឃ្លាត់រ មេឌីខល & ហ៊ែល ស៊ីទីស** ៩៣៥

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិចផ្លរ អេស៊ា ត្រាវ៉ែល & ទ្រេដ** ៩៣៧

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំ ម៉ីហ្សនេស គ្រុប** ៩៣៩

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទី គ្រុប** ៩៤១

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ែន សារុន ជេ,ទី,ភ្ញូហាត អ៊ិន ទេសមេន/ឌី,អូ,ធី,អេស,អេ** ៩៤៣

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម្សៅម្រេច ហាងរនាគ ខូ អិលធីឌី** ៩៤៥

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈ័យ អ៊ិនធើណេសិនណល** ៩៤៧

ព្រះរាជក្រម

នស/រកម/០១០៧/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

7/13

ច្បាប់

ស្តីពី

មូលបត្ររដ្ឋ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាកាតព្វកិច្ចទូទាត់សងចំពោះតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ ត្រូវចំណាយក្នុងតម្លៃមួយដែលទាបបំផុត សម្រាប់មូលបត្ររយៈពេលមធ្យម ឬ វែង ហើយត្រូវសមស្របទៅតាមកម្រិតហានិភ័យ ដែលអាចកើតមានឡើង និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានដូចខាងក្រោម:

១-**មូលបត្ររដ្ឋ** សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់នេះ រួមមាន:

ក-ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ ។

ខ-សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ ។

គ-សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណា ឬ អត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។

ឃ-មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ ។

ង-មូលបត្ររដ្ឋផ្សេងៗដទៃទៀត ។

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រ ដែលបោះផ្សាយដោយអាជ្ញាធរខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះទេ ។

២-មូលបត្ររដ្ឋមិនអាចជួញដូរបាន សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឱ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬ សន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិមានសិទ្ធិស្នើសុំការទូទាត់សងមុនកាលប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

៣-វិញ្ញាបនប័ត្រមូលបត្ររដ្ឋ សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាលកម្ពុ-ជា ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ ។

៤-គណនី សំដៅដល់គណនីទូទៅ និងគណនីពិសេសរបស់រតនាគារជាតិដូចមានចែងនៅក្នុងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងគណនីពិសេសផ្សេងទៀត ដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៥-សន្តតិជន សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតក-ជនតាមរយៈសន្តតិកម្ម ។

៦-សន្តតិកម្ម សំដៅដល់ការផ្ទេរសិទ្ធិ និងករណីកិច្ចរបស់មតកជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់ ។

៧-មូលនិធិផ្សេងៗ សំដៅដល់មូលនិធិពិសេស ដែលបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ មូលនិធិនេះ ត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការមួយជាក់លាក់ក្នុងគោលបំណងច្បាស់លាស់ ហើយប្រតិបត្តិការនៃមូលនិធិនេះ មិនពាក់ព័ន្ធនឹងថវិកាចំណូល-ចំណាយរបស់រាជរដ្ឋាភិបាល ដែលស្ថិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នោះទេ លើកលែងតែមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ហៅកាត់ថា **ម.គ.ម.រ.** ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។

៨-មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ (ម.គ.ម.រ.) សំដៅដល់ប្រាក់ដែលផ្តល់ឱ្យ

ដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់កិច្ចការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋទាំងឡាយណាដែលបានបោះផ្សាយរួច ។ មូលនិធិនេះ មិនមែនជាមូលនិធិដែលបង្កើតឡើងក្នុងគោលដៅមនុស្សធម៌នោះទេ ។

៩-ប្រធានស្ថាប័នរដ្ឋបាលកណ្តាល សំដៅដល់ថ្នាក់ដឹកនាំក្រសួងនានា និងថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀត ដែលទទួលបានសិទ្ធិស្របច្បាប់ និងមានតួនាទីស្មើក្រសួងនានា ។

១០-កាលប្រតិទាន សំដៅដល់កាលបរិច្ឆេទមូលបត្រត្រូវដល់កាលកំណត់សង ។

១១-រដ្ឋមន្ត្រី សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១២-ច្បាប់ធនាគារជាតិ សំដៅដល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ។

១៣-ក្រសួង សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ២

ការបោះផ្សាយ និង ការដាក់លក់មូលបត្ររដ្ឋ

មាត្រា ៣.–

ការបោះផ្សាយ និងការដាក់លក់មូលបត្ររដ្ឋ ត្រូវអនុវត្តដូចខាងក្រោម ៖

ក-មានតែរដ្ឋមន្ត្រីម្នាក់ប៉ុណ្ណោះ ដែលអាចបោះផ្សាយមូលបត្ររដ្ឋក្នុងក្របខ័ណ្ឌចំណាយនៃ ម.គ.ម.រ. ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។ រដ្ឋមន្ត្រីអាចទិញ ទូទាត់សង និងផ្តល់ប្រាក់វិញនូវរាល់មូលបត្ររដ្ឋដែលដល់ ឬ មិនទាន់ដល់កាលប្រតិទាន ។ ប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋត្រូវបានធានាដោយគ្មានលក្ខខណ្ឌពីរាជរដ្ឋាភិបាល ។

ខ-រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធ ដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រី ត្រូវទទួលបន្ទុករាល់កិច្ចការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ លើកលែងតែរដ្ឋមន្ត្រីបានផ្ទេរសិទ្ធិអំណាចជាលាយលក្ខណ៍អក្សរទៅឱ្យស្ថាប័នរដ្ឋដទៃទៀត ។

គ-ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ធនាគារជាតិ រាល់ការងារបច្ចេកទេស និងប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ដោយមានការណែនាំពីរដ្ឋមន្ត្រី ដែលមានចែងនៅក្នុងអនុក្រឹត្យ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវបង្កើតនូវនីតិវិធីដើម្បីបែងចែកឱ្យដាច់ដោយឡែកពីគ្នានូវមុខងារប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ និងមុខងារគោលនយោបាយរូបិយវត្ថុ ។

ប្រសិនបើប្រធានស្ថាប័នរដ្ឋបាលកណ្តាលណាមួយ ដែលគ្រប់គ្រងគណនី និងមូលនិធិដទៃទៀត ដែលស្ថិតនៅក្រោមច្បាប់ផ្សេង ហើយមានបំណងបោះផ្សាយមូលបត្ររដ្ឋ ត្រូវធ្វើសំណើទៅរដ្ឋមន្ត្រីអំពីការបោះផ្សាយមូលបត្រនោះ ។

អាជ្ញាធរខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈមិនអាចបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដោយពុំមានការយល់ព្រមពីរដ្ឋមន្ត្រីជាមុននោះទេ ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិ ឬ ជារូបិយប័ណ្ណបរទេស ។

មាត្រា ៤.-

ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រូវបានអនុម័តដោយរដ្ឋសភា ។

នាយករដ្ឋមន្ត្រី ត្រូវធ្វើជូនរដ្ឋសភានូវចំនួនទឹកប្រាក់សរុបនៃមូលបត្ររដ្ឋ ដែលត្រូវបោះផ្សាយ ដែលជាផ្នែកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ។

នាយករដ្ឋមន្ត្រី អាចធ្វើសំណើទៅរដ្ឋសភា ដើម្បីសុំការអនុម័តលើការបោះផ្សាយមូលបត្ររដ្ឋបន្ថែម ទៅលើចំនួនទឹកប្រាក់សរុប ដែលរដ្ឋសភាបានអនុម័តរួចហើយ ។ ជាមួយនឹងសំណើនេះ នាយករដ្ឋមន្ត្រី ត្រូវផ្តល់នូវការពន្យល់ឱ្យបានច្បាស់លាស់នូវហេតុផលដ៏ចាំបាច់នៃការបោះផ្សាយមូលបត្របន្ថែមនេះ ។

មាត្រា ៥.—

មូលបត្ររដ្ឋត្រូវបានបោះផ្សាយលក់ជាសាធារណៈ នៅលើទីផ្សារក្នុងតម្លៃសមស្រប តាមវិសាលភាពដែលអាចធ្វើទៅបាន ព្រមទាំងផ្ដល់ឱកាសស្មើភាពគ្នាដល់សាធារណជន ក្នុងការចូលរួមទិញមូលបត្រទាំងនេះ ។

រដ្ឋមន្ត្រីអាចសម្រេចលើការបោះផ្សាយមូលបត្ររដ្ឋ តាមវិធីសាស្ត្រផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលកំណត់ក្នុងអនុក្រឹត្យ ។ ការបោះផ្សាយមូលបត្ររដ្ឋរួមទាំងរបៀបបោះផ្សាយ និងអត្រាការប្រាក់ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

មូលបត្ររដ្ឋត្រូវបានដាក់លក់ជាសាធារណៈ នៅទីផ្សារដំបូងដោយការដេញថ្លៃ ។ នៅពេលដែលមានមូលបត្ររដ្ឋនៅសល់ពីការលក់ដោយការដេញថ្លៃ រដ្ឋមន្ត្រីអាចប្រើប្រាស់គណនីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទិញមូលបត្រទាំងនោះមកវិញតាមលក្ខខណ្ឌ និង រយៈពេលដូចដែលបានលក់តាមរយៈការដេញថ្លៃ ។

មាត្រា ៦.—

រាល់បញ្ហាទាក់ទងនឹងការគ្រប់គ្រងវិញ្ញាបនប័ត្រមូលបត្ររដ្ឋ ការចុះបញ្ជី និងការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

ជំពូកទី ៣

មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

មាត្រា ៧.—

រាជរដ្ឋាភិបាលត្រូវបង្កើត ម.គ.ម.រ. ដើម្បីគ្រប់គ្រងការបោះផ្សាយ និងការទូទាត់សងមូលបត្ររដ្ឋ ប្រកបដោយប្រសិទ្ធភាព និងបញ្ហាពាក់ព័ន្ធផ្សេងទៀត ។

ម.គ.ម.រ. អាចធ្វើប្រតិបត្តិការ ក្រៅនីតិវិធីហិរញ្ញវត្ថុ ដែលកំណត់ដោយច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

៩/១៣

មាត្រា ៨.-

រដ្ឋមន្ត្រីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.រ.** ។

រដ្ឋមន្ត្រីប្រគល់សិទ្ធិ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.រ.** ។

ក្នុងករណីមានការប្រគល់សិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនទៅរដ្ឋមន្ត្រីអំពីការទូទាត់លើគណនីរបស់ ម.គ.ម.រ. នៅមុនដំណាច់ខែកុម្ភៈនៃឆ្នាំសារពើពន្ធបន្ទាប់ ។ របាយការណ៍ប្រចាំឆ្នាំនេះ ត្រូវមានចំណុចដូចខាងក្រោម :

-របាយការណ៍ស្តីពីស្ថានភាពទូទៅ និងការវិភាគលើ **ម.គ.ម.រ.**

-តារាងតុល្យការ

-របាយការណ៍ចំណូល-ចំណាយ

-របាយការណ៍លំហូរសាច់ប្រាក់ និងឯកសារដើមផ្សេងៗ

-ឯកសារពាក់ព័ន្ធផ្សេងៗដែលទាក់ទងនឹងការទូទាត់លើគណនីរបស់ **ម.គ.ម.រ.** ។

បញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងប្រតិបត្តិការ និងការគ្រប់គ្រងនៃ **ម.គ.ម.រ.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៩.-

ប្រភពហិរញ្ញវត្ថុរបស់ **ម.គ.ម.រ.** អាចបានមកពីប្រភពចំណូលដូចខាងក្រោម :

-ចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ

-ចំណូលការប្រាក់ដែលបានពីគណនីប្រាក់បញ្ញើ និងមូលនិធិផ្សេងទៀត

-អតិរេកនៃការទូទាត់ប្រចាំឆ្នាំ

-វិភាគទានពីរាជរដ្ឋាភិបាល

-ចំណូលបានពីប្រតិបត្តិការផ្សេងៗរបស់ **ម.គ.ម.រ.** ។

ម.គ.ម.រ. ត្រូវបានប្រើប្រាស់ដើម្បីបំពេញគោលដៅដូចខាងក្រោម :

-ទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋដែលបានបោះផ្សាយ

។

-ដាក់ទៅក្នុងគណនី និងក្នុងមូលនិធិផ្សេងៗនូវប្រាក់ចំណូលរបស់ ម.គ.ម.រ.

-ទូទាត់សងរាល់ចំណាយចាំបាច់នៃការគ្រប់គ្រង ម.គ.ម.រ.

-អាចទិញមូលបត្ររដ្ឋ និងសញ្ញាប័ណ្ណមហាជនផ្សេងៗ និងដាក់ប្រាក់បញ្ញើរយៈពេលខ្លី ឬ ផ្តល់ឥណទានរយៈពេលខ្លីទៅឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនានា ។ រដ្ឋមន្ត្រីអាចចេញប្រកាសឱ្យប្រើប្រាស់សាច់ប្រាក់ ដែលនៅសល់ក្នុងគោលបំណងផ្សេងៗ ។

មាត្រា ១០.-

រដ្ឋមន្ត្រីត្រូវធ្វើផែនការប្រតិបត្តិការរបស់ ម.គ.ម.រ. ហៅថា "ផែនការប្រតិបត្តិការ" ដោយលើកមកពិចារណានូវតម្រូវការចាំបាច់នៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ។

រដ្ឋមន្ត្រីត្រូវដាក់ផែនការប្រតិបត្តិការនេះ ជូនទៅគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សានិងសម្រេច ។

ជំពូកទី ៤
ការត្រួតពិនិត្យ និងតួនាទីរបស់រដ្ឋក្នុងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

មាត្រា ១១.-

អាជ្ញាធរសវនកម្មជាតិ អាចត្រួតពិនិត្យនូវរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋនានារបស់ក្រសួង និងរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានផ្ទេរសិទ្ធិដោយរដ្ឋមន្ត្រី ដោយអនុលោមតាមច្បាប់នេះ ។

នាយកដ្ឋាន ឬ អង្គភាពទទួលបន្ទុកត្រួតពិនិត្យរបស់ក្រសួង និងធនាគារជាតិនៃកម្ពុជា ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធរបស់ខ្លួន ដែលទទួល

ខុសត្រូវនូវរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋទៅតាមការទទួលខុសត្រូវរៀងៗខ្លួន ហើយត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី និងទេសាភិបាលធនាគារជាតិនៃកម្ពុជា ពិនិត្យ និងផ្តល់អនុសាសន៍ ។

មាត្រា ១២.-

គណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ អាចត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីដើម្បីពិភាក្សា និងសម្រេចលើគោលនយោបាយសំខាន់ៗដែលទាក់ទងនឹងការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ ។

គណៈកម្មាធិការចម្រុះនេះត្រូវមានសមាសភាពដូចតទៅ :

- រដ្ឋមន្ត្រី
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា
- ប្រធានស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀតដែលពាក់ព័ន្ធ ប្រសិនបើមាន
- ជំនាញការមកពីផ្នែកឯកជន ។

រដ្ឋមន្ត្រីអាចបង្កើតក្រុមការងារជំនាញ ដើម្បីសិក្សាពីវិធីសាស្ត្រ និងមធ្យោបាយសម្រាប់អភិវឌ្ឍទីផ្សារដំបូង និងទីផ្សារបន្ទាប់នៃមូលបត្ររដ្ឋឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់អនុសាសន៍ជូនដល់រដ្ឋមន្ត្រី ។

មាត្រា ១៣.-

បន្ទាប់ពីបានពិភាក្សា និងសម្រេចពីគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីត្រូវដាក់របាយការណ៍ប្រចាំឆ្នាំ ស្តីពីប្រតិបត្តិការបំណុលសាធារណៈរបស់ក្រសួងក្នុងនោះរួមមានព័ត៌មានទាំងអស់ ដែលទាក់ទងនឹងបំណុលសាធារណៈសរុប បំណុលសាធារណៈសុទ្ធ ឥណប្រតិទានតារាងពេលវេលាសងប្រាក់ដើម និងការប្រាក់ ព័ត៌មានម្ចាស់បំណុលសាធារណៈ ប្រតិបត្តិ-ការរបស់ម.គ.ម.រ. និងផ្តល់សេចក្តីពន្យល់លើយុទ្ធសាស្ត្រហិរញ្ញប្បទាន សម្រាប់ឆ្នាំសារពើ-ពន្ធបច្ចុប្បន្ន និង សម្រាប់ ៥ឆ្នាំ (ប្រាំឆ្នាំ) សារពើពន្ធបន្តបន្ទាប់ជូនទៅរដ្ឋសភា ។

11/12

មាត្រា ១៤.-

ក្នុងករណីចាំបាច់ដើម្បីឱ្យការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ រដ្ឋមន្ត្រីអាចស្នើសុំប្រធានស្ថាប័នរដ្ឋបាលកណ្តាលបង្ហាញនូវឯកសារពាក់ព័ន្ធផ្សេងៗ ។

បន្ទាប់ពីទទួលបានការស្នើសុំឱ្យបង្ហាញនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី ១ ប្រធានស្ថាប័នរដ្ឋបាលកណ្តាលពាក់ព័ន្ធ ត្រូវអនុវត្តតាមការស្នើសុំនោះ លើកលែងតែមានមូលហេតុពិសេសផ្សេងទៀត ។

មាត្រា ១៥.-

រាជរដ្ឋាភិបាលមិនត្រូវបង្កើតកិច្ចសន្យា ឬ ការបញ្ចាំណាមួយ ឬ ការដាក់ទ្រព្យសកម្មសាធារណៈ ឬ ធនធានផ្សេងៗ ដើម្បីធានាការបោះផ្សាយមូលបត្ររដ្ឋឡើយ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទ្រព្យសកម្មសាធារណៈ និងប្រាក់ចំណូលរបស់រដ្ឋ ត្រូវបានការពារពីការរឹបអូស និងការហាមឃាត់ផ្សេងៗ ។

សិទ្ធិប្តឹងទាមទារសំណងនូវចំនួនទឹកប្រាក់នៃមូលបត្ររដ្ឋត្រូវអនុវត្តក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ ចំពោះប្រាក់ដើម និង ២ (ពីរ)ឆ្នាំ ចំពោះការប្រាក់គិតចាប់ពីកាលបរិច្ឆេទឥណប្រតិទាន ។

ជំពូកទី ៥
ទោសប្បញ្ញត្តិ

មាត្រា ១៦.-

បុគ្គលដែលក្លែងមូលបត្ររដ្ឋ តាមរូបភាពណាក៏ដោយ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ១៧.-

បុគ្គល ឬមន្ត្រី ដែលពាក់ព័ន្ធក្នុងការអនុវត្តដេញថ្លៃ ឬ ពាក់ព័ន្ធក្នុងកាតព្វកិច្ចផ្សេងទៀត ហើយមិនបានបំពេញត្រឹមត្រូវតាមការកំណត់របស់ច្បាប់នេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ជំពូកទី ៦

អន្តរប្បញ្ញត្តិ

មាត្រា ១៨.-

ក្នុងករណីមូលបត្ររដ្ឋណាមួយ ដែលបានបោះផ្សាយហើយ មិនទាន់បានទូទាត់សង ដោយគិតត្រឹមថ្ងៃដែលច្បាប់នេះចូលជាធរមាន មូលបត្ររដ្ឋទាំងនោះ ត្រូវតែទទួលបានការទូទាត់សងតាមគណនី និងនីតិវិធីដែលបានបោះផ្សាយ ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០១០៧.០១៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ៣១ ធ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៥៣៩

យើង

ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ÷

1/3

១	អៀម រ៉ា	ប	ឧត្តមមន្ត្រី	ថ្នាក់លេខ ៥

មាត្រា ២.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ÷

១	អេង តាយម៉េង	ប	អនុមន្ត្រី	ថ្នាក់លេខ ៧
២	មាស សុផល	ប	អនុមន្ត្រី	ថ្នាក់លេខ ៨
៣	អ៊ុក សីហា	ស	អនុមន្ត្រី	ថ្នាក់លេខ ៨
៤	ពៅ ស្មើ	ប	អនុមន្ត្រី	ថ្នាក់លេខ ៨
៥	ខិន ពន្លក	ប	អនុមន្ត្រី	ថ្នាក់លេខ ៩
៦	អ៊ុ សុធី	ប	អនុមន្ត្រី	ថ្នាក់លេខ ៩
៧	ហោរ ស៊ីម៉េន	ប	អនុមន្ត្រី	ថ្នាក់លេខ ១០
៨	ម៉ម សុវណ្ណ	ប	អនុមន្ត្រី	ថ្នាក់លេខ ១០
៩	កង សៀងចេង	ប	អនុមន្ត្រី	ថ្នាក់លេខ ១០
១០	គួង គុសល	ប	អនុមន្ត្រី	ថ្នាក់លេខ ១០
១១	ម៉ាក សុខារ៉ាវុធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
១២	គេង រិទ្ធិនី	ស	អនុមន្ត្រី	ថ្នាក់លេខ ១១
១៣	ឃ៉ាន់ ប៊ុណ្ណុច	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
១៤	សួរ វីណារិន	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
១៥	ហាច សោភា	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
១៦	ច័ន្ទខែម នាត់	ស	អនុមន្ត្រី	ថ្នាក់លេខ ១១
១៧	ហេង ភារិទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
១៨	អៀង សាក់និដា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
១៩	ស៊ិន ខំណ្ឌី	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២០	សៅ ស៊ីធួន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២

២១	ឌិន ពេងរ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២២	ឡូច ម៉ុនថន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៣	កែន សេរីរដ្ឋា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៤	គិន ឆវីវ៉ាន់	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៥	ឈុប សុធារិទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៦	ម៉ិន ឡុំ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៧	ស៊ិ រ៉ាមុនី	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៨	ម៉ាន់ មួយ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
២៩	ជា ឈឿន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣០	យ៉ឹម ចំណាន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣១	អ៊ុំ ពិសី	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣២	អោង ម៉ុនឈឿន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៣	ស៊ុយ ឆា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៤	តាំង ចិន្តា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៥	ជឹម កល្យាណី	ស	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៦	ខាត់ សុវណ្ណ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៧	គឹម ឈុង	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៨	ស៊ឹម សារឿន	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៣៩	ម៉ុក សុភា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤០	អ៊ែ ទន្សចន្ទ្រសោ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤១	ញូង គុណ្ណា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤២	ស្រី ម៉ារ៉ូណា	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤៣	ឡុង សំគៀត	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤៤	ឈឹម សាយ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤៥	ឡុង ចន្ទរិទ្ធិ	ប	អនុមន្ត្រី	ថ្នាក់លេខ ១២

៤៦	គាន់ ទិមុល	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤៧	ឈិត សុផល	ប	អនុមន្ត្រី	ថ្នាក់លេខ ១២
៤៨	គីម ណេង	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៤៩	ថៃ ចន្ថា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥០	លី សុគន្ធ	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥១	ផាន់ នារី	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥២	រាត់ ស៊ិទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៣	ញាណា ផល្លា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៤	អ៊ុក ណារ៉ាន់	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៥	ជា ម៉េងឡៀង	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៦	អ៊ា លាងហ៊ន់	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៧	ម៉ក់ បូរ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៨	ឃួរ និត្យសុខាចន្ទ្រា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥៩	ម៉េង ម៉ូល្លិកា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦០	លួន ភារ៉ែណល	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦១	អេង គីមសាន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦២	ឃួរ ពិសិដ្ឋ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៣	ជា ណារ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៤	ពុទ្ធ សុរិទ្ធី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៥	សួស សារិន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៦	ហេង ចាន់ធឿន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៧	ចា ស៊ុលលី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៨	សំ ភក្ដជា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦៩	ជា បញ្ញារិទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧០	អ៊ុច ភាន់ដារ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣

៧១	អ៊ុំ ចិន្តណារិទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧២	ជាញ់ សេរី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧៣	ជៀក ឫទ្ធី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧៤	ធាន សុវណ្ណា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧៥	កៅ លាប	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧៦	ជី សាន	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧៧	សុវណ្ណ ប្រសើរ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧៨	គីម សេរីគិត	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៧៩	ខៀវ វិសុទ្ធ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨០	សែម ស៊ិនដារ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨១	ទ្រី សៀកឡោ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨២	គីម មករា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨៣	អ៊ឹម បញ្ញារិទ្ធី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤

មាត្រា ៣.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ÷

១	គីម ឡាន់ណី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៩
២	សុខខេង នរិន្ទ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៩
៣	អ៊ុង សំអឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១០
៤	អ៊ឹង យទីត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១០
៥	ជីវ ឡា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១០
៦	សុខ ខុម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១០
៧	យឹម ចាន់ណារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១០
៨	ចក់ សុខមិត្តបុត្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
៩	គុច ចិន្តធឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១០	ស្រី អូន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១

១១	ឈុប ផារី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១២	គង់ អក្ខរា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៣	ចាប យុធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៤	ជិន ចំរើន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៥	ឯក ម៉ែនរិទ្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៦	នេត ណាថ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៧	ឃុន ឃុង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៨	ហ៊ុយ ផលទុឌី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
១៩	ខ៊ែត បុល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
២០	ជ្រិន សុខា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២១	ឆា ធីរោ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២២	នៅ ការុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៣	ហេង ឃុង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៤	អ៊ុក លីឃីម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៥	រស់ ឆានសុខ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៦	ជិន ទិបុល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៧	អ៊ែល សំអាត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៨	យុន សុធិតា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
២៩	ឡុង ពន្លក	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣០	ខាន់ នួច	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣១	ឈាំង គិរុណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣២	សោម ពៅ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៣	នួច វីណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៤	សួន ហាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៥	ស៊ុំ ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៦	ឡាំ សុគ៌ក្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៧	ស៊ីម គង់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២

៣៨	ស៊ិន ឧត្តី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៣៩	ម៉ី គារជារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤០	ឡុង ខេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤១	យិន ម៉ុនណាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤២	ឡៀន សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៣	អ៊ិន សុខា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៤	គួង លីណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៥	យុន វិវុទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៦	អ៊ូង ម៉ុនណាល់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៧	គិន សិត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៨	ឆា ចន្ទសុធារី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៤៩	អៀន វិចិត្រ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥០	ព្រុំ ទុល្សី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥១	សារុន សំបូរ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥២	ម៉ៅ វណ្ណចន្ទ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៣	ហាង វិបុល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៤	សុខ សុវ៉ាណ្ណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៥	អ៊ុំ សិរីវុឌ្ឍ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៦	គិន វិជ្ជារ៉ាវុឌ្ឍ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៧	អ៊ុច សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៨	មាស រិទ្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៥៩	ឌុយ សេរីវុឌ្ឍា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៦០	សួរ វណ្ណនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៦១	គីន យ៉ាងលី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៦២	មាស សុធនវឌ្ឍនៈ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៦៣	គីម សុវណ្ណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៦៤	ស៊ុន គង់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣

៦៥	ហេង សម្បត្តិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៦៦	ឃូ អៀងហួត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៦៧	សាខុន ប៊ុះ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៦៨	ហួត ពិសិដ្ឋ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៦៩	សាន្ត សុជាតិលក្ខិណា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧០	សរ កុសល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧១	ឡាយ ឈន្ទរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧២	ងុំ សុខជា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៣	អ៊ុង ឫទ្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៤	សុខ ទង់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៥	ចៅ ជ័រឡេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៦	ស៊ី សុចន្ថាយ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៧	ស៊ូ ទីរះ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៨	ទង់ គុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៧៩	ភួច គន្ធារះ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨០	ហ៊ុល ទារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨១	ឈ្លាង គីវុធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨២	គឹម ជន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៣	ពូក ម៉ុនចេត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៤	ឆិត សុវណ្ណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៥	ឆេង សុជាតិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៦	គង ករណី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៧	អ៊ូ ចិន្ត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៨	ឱស សាភឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៨៩	ឈុន ជាតា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩០	គួច សុភី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩១	ឆិត សៅ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣

៩២	មាស មុនិន្ទ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៣	មិញ ម៉ុនលី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៤	ឯម រ៉ូនី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៥	លី ស្រេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៦	សឿង ខេមរៈ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៧	ឃឹន ស៊ួង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៨	សួស សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩៩	ឌូ កុយ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០០	ជា ចន្ទ្រណារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០១	ម៉ៅ មករា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០២	សឿន សិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៣	នួច ចណ្ណារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៤	អួន បូរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៥	លី សៀកម៉េង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៦	ម៉ៃ ចណ្ណៈ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៧	យុយ គុយនី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៨	ឆុង សុភលក្ខ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០៩	ឌេស នារីរិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១០	ទឹម ណូរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១១	ស្វាយ ប្រុស	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១២	ផាន់ ផា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៣	ហេង សាំងហ៊ី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៤	ឃឹម ហ៊ុយលីម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៥	ជុំ សោភ័ណ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៦	មាស សុម៉ូនិកា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៧	ឈឹន សុធន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១៨	ឯក ផាណិត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣

១១៩	មាស ឆាន់ណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២០	អ៊ុយ ភាម៉ាល់	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២១	គ្រី គីរវត្ត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២២	ឈឿន រ៉ាចត្ថី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៣	ឡាំ សៅឡេង	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៤	អ៊ា ផុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៥	សុខ ទុឡឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៦	សាម៉េង សេរីបុណ្យ	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៧	នូ សុខា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៨	អៀ គីមឆេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១២៩	អ៊ុន ម៉ានី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣០	ជា ឡេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣១	ជា សម្បត្តិ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣២	គន់ នី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៣	អ៊ូ រតនះ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៤	ឈីន និត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៥	សាន សុធារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៦	អាត់ ជាសុខសិអាត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៧	ឡឹក ជាណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៨	ហង់ ដារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៣៩	នាង នី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤០	ឈឿង កេសរេ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤១	ជឹម សុគន្ធា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤២	ប៊ុណ្ណ ខ្លា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៣	យ៉េង តិរម្យ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៤	ទឹម សុខុម	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៥	ឃួត គីមស្រ៊ុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣

១៤៦	គង់ គឹមស្រេង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៧	ហួ សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៨	អេង សុធា	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១៤៩	ជាត អ៊ីណាល់	ប.	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥០	សួន សុខឈាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥១	ស៊ិន សុវណ្ណតារា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥២	ជួន ចាន់និត្យា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៣	ឈុន សុផល	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៤	ហ៊ូ ចន្ទ្រទិព្វិកា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៥	ទី ឡាយមិថុនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៦	ម៉ែន បញ្ញារតន៍	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៧	ជាន់ រដ្ឋា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៨	សុខា សោភ័ណ្ឌ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥៩	អ៊ុន ពិសី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦០	ហ៊ា ភាព	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦១	ឌីមគី យ៉ារ៉ូ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦២	រិន កែវ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៣	ហុង សុទ្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៤	ម៉ិន ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៥	រ៉ូ បូរី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៦	ជោង ពីណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៧	ហ៊ាន់ គន្ធា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៨	ឃួន សុខាន់ឌី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៦៩	សេង វឌ្ឍា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧០	ម៉ី ស៊ីធីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧១	ស៊ី ជីន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧២	យីហួត យូហួ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

១៧៣	ឃួន ម៉ុនសែ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៤	ឈិញ នីដា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៥	អ៊ុច ឌន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៦	ឡាយ ចាន់ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៧	គិត ចាន់ថៃ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៨	ម៉ៅ គន្ធា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៧៩	រ៉ុង ម៉ុនរ៉ៃ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨០	ស្រី ស៊ុនលាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨១	ស្រី ស៊ីណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨២	ម៉ុយ វណ្ណនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨៣	ឃួន ពុទ្ធថា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨៤	នួន ចន្ណារា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨៥	ឈុម ឈាវី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨៦	ស៊ុយ ម៉ុនតូ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៨៧	អ៊ូ ម៉ានីរ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

មាត្រា ៤.-

រាល់ការផ្លាស់ប្ដូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល នៅក្រោយពេលបញ្ចប់ការកំណត់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវអនុវត្តទាំងស្រុងតាមខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៧.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរល.០៦១២.៥៧៥

លេខ: ៤៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ មករា ឆ្នាំ២០០៧

អគ្គលេខាធិការរបស់រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៥៤០

យើង

ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម ៖

១	សុខ ម៉ារិត	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
២	ជៀប រ៉ា	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
៣	ទ៉េង សាភ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៤	ម៉េង ម៉ិចនិត	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៥	ម៉ុន សុភាព	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦	ពេជ សូរិយា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧	កែវ សរ៉ាត់	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៨	សុខ រិទ្ធី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
៩	កាន់ សុខឿន	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤

មាត្រា ២.-

រាល់ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល នៅក្រោយពេលបញ្ចប់ការកំណត់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវអនុវត្តទាំងស្រុងតាមខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៥.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសប្តាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៦១២.៥៧៦

១០៥ ... ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ០១ ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/ ០១០៧ /០៤១

យើង

ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម ៖

១	ស្វាយ សន្ធះ	ប	អនុមន្ត្រី	ថ្នាក់លេខ ៨
២	មាស ធុន	ប	អនុមន្ត្រី	ថ្នាក់លេខ ១០
៣	ណន ធារី	ប	អនុមន្ត្រី	ថ្នាក់លេខ ១១
៤	ទីន ណារី	ស	អនុមន្ត្រី	ថ្នាក់លេខ ១២
៥	ធន់ ស្លាគ្ន	ស	អនុមន្ត្រី	ថ្នាក់លេខ ១៣
៦	ឡើវ យុជា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៧	ម៉ុខ សត្យា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៨	ប្រាក់ ស៊ុនធី	ប	អនុមន្ត្រី	ថ្នាក់លេខ ១៣
៩	ហួន ឈោខ	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១០	ហែប លីរ៉ា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
១១	គង់ ចរិយ៉ា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
១២	យាង សុវណ្ណចន្ទា	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៣	អែម បុន្ថា	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៤	ឌួ សំអាត	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៥	អ៊ុល គន្ធារ	ស	អនុមន្ត្រី	ថ្នាក់លេខ ១៤
១៦	ជុំ ស៊ុនណាល់	ប	អនុមន្ត្រី	ថ្នាក់លេខ ១៤

មាត្រា ២.

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១	ពាង សារី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ	ថ្នាក់លេខ ៧
២	សុខ ពុទ្ធចឿន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ	ថ្នាក់លេខ ៨

មាត្រា ៣.

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម ÷

១	ជា សុន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៥
២	គីម ស៊ុនួន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៧

៣	សោម ទ័ាន់ថូ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៧
៤	ចាន់ ធារសនា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ៧
៥	សូ ឌណាសុត	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១១
៦	តាន់ សុធារី	ស	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៧	ហ៊ីុខ សុតា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១២
៨	សោម សគុណា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
៩	មាស សុភាព	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១០	ប៊ុល ដារ៉ារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៣
១១	ហ៊ាន ចំនួដារ៉ា	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១២	សួស ពុទ្ធារិទ្ធ	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៣	ម៉ៅ គីមលាង	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៤	កោះ ឆាន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤
១៥	គង់ គន្ធី	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់	ថ្នាក់លេខ ១៤

មាត្រា ៤.-

រាល់ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល នៅក្រោយពេលបញ្ចប់ការកំណត់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវអនុវត្តទាំងស្រុងតាមខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៧.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស/រកត.០៦១២.៥៧៧

លេខ : ៤៧ ច.ល

[illegible]ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៧

[illegible]រាជរដ្ឋាភិបាល

[illegible] ជិនអេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

សម្រេច

មាត្រា១ : ត្រូវបានដាក់ឱ្យលោក **មួង សុខត្ថិ** វរមន្ត្រី ថ្នាក់លេខ ៣ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧ នេះតទៅ ។

មាត្រា២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការស៊ីវិលចំនួន ០២ រូបនៃក្រសួងព័ត៌មាន ដូចមានរាយនាមខាងក្រោម :

១- លោក វណ្ណថា វណ្ណរ័ត្ន ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

២- លោក យ៉ែម ណាយ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានមណ្ឌលព័ត៌មាន ជំនួសលោក មួង សុវត្ថិ ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន ០២រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

១-លោក **វ៉ន្ត សុគៈ**

២-លោក **ហ៊ុន សុន**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ០៣រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច កសាងនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ លើវិស័យកសិកម្ម និងជនបទ នៅខេត្តកណ្តាល ដូចមាន រាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :

-ឯកឧត្តម **វំនួ ចិះ**

ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

១-លោក **ឯម សុគន្ធ**

២-លោក **សាម្ភត ឡឿន**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគ ដែលបានផ្ទេរទៅគណនីលទ្ធផល (តាមការគិតរំលស់ អចលកម្ម)

- កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគដែលបានកត់ត្រា បន្ថែមចូលគណនីលទ្ធផលចរន្ត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បូកបន្តនៃចំណែកឧបត្ថម្ភកធនវិនិយោគ ដែលបានផ្ទេរទៅគណនី លទ្ធផលដោយដោយជំរះជាមួយគណនី ឧបត្ថម្ភកធន វិនិយោគដែលបានទទួល

- កត់ត្រាតំលៃគណនេយ្យនៃ ចំណែកសកម្មដែលបានពីឧបត្ថម្ភកធនវិនិយោគហើយបានជំរះមុនកាលកំណត់ប្រើប្រាស់

សមតុល្យ : ឥណទាយិក បង្ហាញចំនួនទឹកប្រាក់បូកបន្តនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

__ចំណាំ__ : គណនីលេខ ១៣៩ ត្រូវចែកជាអនុគណនីទៅតាមប្រភពដែលផ្តល់ឧបត្ថម្ភកធន ។

១០_គណនី ប្រាក់តំកល់ធានាបានទទួល " លេខ ១៦៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានខេត្ត-ក្រុងទទួលពីការដំកល់ធានាលើសកម្មភាពអាជីវកម្មរបស់អាជីវករ ក្រុមហ៊ុន ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានសងទៅអាជីវករ ឬ ក្រុមហ៊ុនវិញ

- កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានផ្ទេរទៅជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានទទួលពី អាជីវករ ឬ ក្រុមហ៊ុន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តំកល់ធានាសកម្មភាពអាជីវកម្មដែលពុំទាន់បានសង ។

__ចំណាំ__ : គណនីលេខ ១៦៣ ត្រូវចែកទៅជាអនុគណនី ទៅតាមប្រភពដែលបានបង់ប្រាក់ ។

១១_គណនី ការបែងចែកទ្រព្យសម្បត្តិទៅស្រុក ខំណ្ឌ " លេខ ១៨១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មដែលខេត្ត-ក្រុងបានផ្ទេរ ប្រគល់

ទៅស្រុក ខ័ណ្ឌដើម្បីប្រើប្រាស់ តែនៅជាកម្មសិទ្ធរបស់ខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានផ្ទេរ ប្រគល់ទៅស្រុក ខ័ណ្ឌ

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានទទួលពីស្រុក ខ័ណ្ឌផ្ទេរ ប្រគល់មកវិញ

សមតុល្យ : ឥណពន្ធិក បង្ហាញតំលៃអចលកម្មដែលសរុបដែលបានផ្ទេរប្រគល់ទៅស្រុក ខ័ណ្ឌ ។

ចំណាំ : គណនីលេខ ១៨១ ពុំមានការតាមដានលំអិតទៅតាមអចលកម្មទេ ។

១២-គណនី សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ " លេខ ២០៣ " :

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលខេត្ត-ក្រុងបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ដែលបានផ្ទេរទៅគណនីអចលកម្មពាក់ព័ន្ធ

សមតុល្យ : ឥណពន្ធិក បង្ហាញតំលៃនៃការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍កំពុងធ្វើ ។

១៣-គណនី ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និង សិទ្ធប្រហាក់ប្រហែល " លេខ ២០៥ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬ ទិញប្រកាសនីយបត្រ អាជ្ញាបណ្ណ័ និង សិទ្ធិប្រហាក់ប្រហែល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទិញ បង្កើតប្រកាសនីយបត្រ អាជ្ញាបណ្ណ័ និង សិទ្ធិប្រហាក់ប្រហែល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះប្រកាសនីយបត្រ អាជ្ញាបណ្ណ័ និង សិទ្ធិប្រហាក់ប្រហែលជាមួយគណនីរំលស់ និងគណនី តំលៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬ ជំរះ ។

សមតុល្យ : ឥណពន្ធិក បង្ហាញតំលៃប្រកាសនីយបត្រ អាជ្ញាបណ្ណ័ និង សិទ្ធិប្រហាក់ប្រហែលកំពុងមាន ។

១៤-គណនី ដីធ្លី និងធនធានធម្មជាតិ " លេខ ២១១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែល ខេត្ត-ក្រុង បានពីអំណោយ ទិញ និងបានពីរូបភាពរូបភាពផ្សេងទៀត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែលបានបន្ថយដោយលក់ ធ្វើអំណោយ ឬផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតំលៃដីធ្លីដែលកំពុងគ្រប់គ្រង ។

ចំណាំ : តំលៃដីធ្លីពុំមានការគិតរំលស់ឡើយ ។

១៥_គណនី ការរៀបចំ កែលំអដីធ្លី " លេខ ២១២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលខេត្ត-ក្រុងបានចំណាយលើការកែលំអដីធ្លី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លីពុំទាន់បានជំរះ ។

១៦_គណនី សំណង់ " លេខ ២១៣ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃសំណង់ អាគារដែលបានទិញ សាងសង់ ឬបានពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃសំណង់ អាគារ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃសំណង់ អាគារដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃសំណង់ អាគារដែលកំពុងមាន ។

ចំណាំ : គណនីលេខ ២១៣ ត្រូវចែកទៅជាអនុគណនីសំរាប់ អាគារ ការរៀបចំកែលំអអាគារ និង សំរាប់សំណង់ផ្សេងៗ ។

១៧_គណនី ហេដ្ឋារចនាសម្ព័ន្ធ " លេខ ២១៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធដែលបានទិញ សាងសង់ ឬបានពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃនៃ ហេដ្ឋារចនាសម្ព័ន្ធដែលកំពុងមាន ។

ចំណាំ : គណនីលេខ ២១៤ ត្រូវចែកទៅជាអនុគណនី សំរាប់បណ្តាញបង្ហូរទឹក និងអនាម័យ បណ្តាញអគ្គិសនី បណ្តាញធារាសាស្ត្រ និង សំរាប់បណ្តាញផ្លូវថ្នល់ ។

១៨-គណនី ឋាបនកម្មបច្ចេកទេស សំភារៈ និងហត្ថូបករណ៍ " លេខ ២១៥ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃឋាបនកម្មបច្ចេសទេស សំភារៈ ហត្ថូបករណ៍ ដែលបានពីការទិញ ពីអំណោយ ឬផ្ទេរមក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃទ្រព្យសម្បត្តិជាឋាបនកម្មបច្ចេសទេស សំភារៈ ហត្ថូបករណ៍ដែលបានចូលជាទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃ ឋាបនកម្មបច្ចេសទេស សំភារៈ ហត្ថូបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជំរះ ឬ បានផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតំលៃឋាបនកម្មបច្ចេសទេស សំភារៈនិង ហត្ថូបករណ៍ដែលកំពុងមាន ។

ចំណាំ : គណនីលេខ ២១៥ ត្រូវចែកទៅជាអនុគណនីសំរាប់ ឋាបនកម្មបច្ចេកទេស សំភារៈ និងគ្រឿងឧបករណ៍ (ហត្ថូបករណ៍) ។

១៩-គណនី អចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់ " លេខ ២១៧ " :

គណនីនេះបើកនៅនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មដែលបានទទួលពីប្រភពផ្សេង មកធ្វើការប្រើប្រាស់ តែនៅជាកម្មសិទ្ធរបស់អ្នកប្រគល់ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង ប្រើប្រាស់

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង ប្រើប្រាស់ហើយបានផ្ទេរចេញវិញ

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មដែលបានទទួលកំពុងធ្វើការគ្រប់គ្រង ប្រើប្រាស់ ។

ចំណាំ : គណនីលេខ ២១៧ ត្រូវចែកទៅជាអនុគណនីសំរាប់ ដីធ្លី សំណង់ ហេដ្ឋារចនាសម្ព័ន្ធ បណ្តាញ ឋាបនកម្មបច្ចេសទេសសំភារៈហត្ថូបករណ៍សំភារៈ និងសំរាប់អចលកម្មបានទទួលមកគ្រប់គ្រងផ្សេងៗទៀត ។

២០-គណនី អចលកម្មរូបីផ្សេងទៀត " លេខ ២១៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃ អចលកម្មរូបីផ្សេងទៀត ដែលខេត្ត-ក្រុង បានទិញសាងសង់ បានពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មរូបីដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ឥណទាន : កត់ត្រាតំលៃ អចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ បានផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណពន្ធ បង្ហាញតំលៃអចលកម្មរូបីផ្សេងទៀតដែលកំពុងមាន ។

ចំណាំ : គណនីលេខ ២១៨ ត្រូវចែកទៅអនុគណនីសំរាប់សំភារៈឧបករណ៍ដឹកជញ្ជូន សំភារៈឧបករណ៍ការិយាល័យ សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម និងសំរាប់អចលកម្មរូបីផ្សេងៗទៀត ។

២១_គណនី រំលស់អចលកម្មអរូបី " លេខ ២៨០ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីរបស់ខេត្ត-ក្រុង ដែលបានទិញ បានពីអំណោយ ពីឧបត្ថម្ភកធនវិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីដែលបានជំរះជាមួយតំលៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីក្នុងឆ្នាំដែលបានចាត់ជាចំណាយថវិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីបូកបន្ត ។

ចំណាំ : - គណនីរំលស់អចលកម្មអរូបី ត្រូវចែកទៅជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយក លេខលំដាប់ទី ៣ នៃគណនីអចលកម្មអរូបី បន្ថែមពីក្រោយលេខ ២៨០ ។

- ការជំរះចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មអរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្ម ស្មើនឹងតំលៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ ។ ការជំរះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់ ។

២២_គណនី រំលស់អចលកម្មរូបី " លេខ ២៨១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី (លើកលែងដីធ្លី) ដែលបានមកពីការទិញ ពីអំណោយ ឬពីឧបត្ថម្ភកធនវិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីដែលបានជំរះជាមួយតំលៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំ ដោយបានចាត់ទុកជាចំណាយថវិកា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបីបូកបន្ត ។

ចំណាំ : - គណនីរំលស់អចលកម្មរូបី ត្រូវចែកកជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី ៣ (គណនីអចលកម្មដែលមាន ៣ លេខ) បន្ថែមពីក្រោយលេខ ២៨១ ឬ ដោយយកលេខ ២ ខ្ទង់ចុងក្រោយនៃគណនីអចលកម្ម (គណនីអចលកម្មដែលមានលេខសំគាល់ ៤ លេខ) បន្ថែមពីក្រោយលេខ ២៨១ ។

- អចលកម្មដែលបានធ្វើរំលស់ស្មើ នឹងតំលៃបញ្ចូល ហើយនៅតែប្រើប្រាស់បាននោះ ត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ និងពុំទាន់ជាកម្មវត្ថុនៃការជំរះឡើយ ។

- ការជំរះខាងឥណពន្ធនៃគណនីរំលស់ពេលលក់ចេញ បោះបង់ចោល បាត់បង់ និង ផ្ទេរ ។

២៣_គណនី អ្នកផ្គត់ផ្គង់ " លេខ ៤០១ " :

គណនីនេះបើនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ដែលបានផ្តល់ទំនិញ សេវាកម្ម ការងារដល់ខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហកៈ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកសំរាប់ផ្ទេរចូលថវិការជ្ជ ឬទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវាការងារ យោងតាមអាណត្តិបើកប្រាក់ ឬបង្វែរពីគណនីផ្សេងមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅ អត្ថគាហកៈ។

ចំណាំ : - គណនីនេះពុំមានគំរូបត្តលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ

- គណនីនេះត្រូវចែកទៅជាអនុគណនីសំរាប់បំណុលឆ្នាំចាស់ និង ឆ្នាំថ្មី ។

២៤_គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) " លេខ ៤១៣ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាគឺយោងតាមរបាយការណ៍ពីអង្គភាពដែលមានការពាក់ពន្ធ័នឹងការគ្រប់គ្រងចំណូលនេះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសាពើពន្ធដែលត្រូវប្រមូល

(ខាងឥណពន្ធ នៃគណនីនេះ បដិភាគនឹងខាងឥណទាននៃគណនីចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨២)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបានទូទាត់

- កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានបន្ថយ ឬ ជំរះ

(ខាងឥណទាននៃគណនីនេះ បដិភាគ នឹងខាង ឥណពន្ធនៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន លេខ ៤៨២)

- ទន្ទឹមនិងលេខនាខាង ឥណទាន នៃគណនីនេះត្រូវមានលេខនាទី ២ គឺកត់ត្រាខាង ឥណពន្ធគណនី ហិរញ្ញវត្ថុ និងខាងឥណទានគណនីចំណូលថវិកាដែលពាក់ព័ន្ធ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូល ។

ចំណាំ : រាល់លើកនៃការបង់ប្រាក់រតនាគារត្រូវធ្វើការវិភាគ រួចកត់ត្រាជាចំណូលក្នុងឆ្នាំ ឬ បន្ថយបំណុលឆ្នាំមុន ។

២៥.គណនី ប្រាក់បៀវត្ស និង លាភការត្រូវសង " លេខ ៤២១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្ស លាភការដែលត្រូវសង និង បានបើកផ្តល់តាមអាណត្តិបើកប្រាក់ ឬ លិខិតស្នើសុំមុនរបស់ខេត្ត-ក្រុង ដែលមានតំលៃប្រហាក់ប្រហែល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនប្រាក់បៀវត្ស និងលាភការដែលបានបើកផ្តល់ជូនខេត្ត-ក្រុង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស និងលាភការដែលត្រូវបើកផ្តល់ជូន ខេត្ត-ក្រុង

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ប្រាក់បៀវត្ស និងលាភការដែលពុំទាន់បានបើកផ្តល់ជូនខេត្ត-ក្រុង

ចំណាំ : គណនីលេខ ៤២១ មានគំរូបាគ្គលេខារបស់ម្ចាស់គណនីដែលជាភ្នាក់ងារបើកផ្តល់ ហើយត្រូវចែកទៅជាអនុគណនីសំរាប់ឆ្នាំចាស់ និងឆ្នាំថ្មី ។

២៦.គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេង ៗ ត្រូវសង " លេខ ៤២២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និង សោហ៊ុយផ្សេងៗមួយចំនួនទៀតដែលត្រូវសងទៅខេត្ត-ក្រុង ដោយផ្ទាល់តាមរយៈភ្នាក់ងារបើកផ្តល់ឬរដ្ឋទេយ្យករបុរេប្រទាន។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយដែលត្រូវបើកផ្តល់ជូនខេត្ត-ក្រុង ដោយយោងតាមអាណត្តិបើកប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បេសកកម្ម និងសោហ៊ុយដែលពុំទាន់បានបើកផ្តល់ជូនខេត្ត-ក្រុង ។

ចំណាំ : គណនីលេខ ៤២២ ពុំចាំបាច់មានគំរូបាគ្គលេខារបស់ម្ចាស់គណនី ហើយត្រូវចែកជាអនុគណនីសំរាប់ឆ្នាំចាស់ និងឆ្នាំថ្មី ។

២៧-គណនី ទំនាក់ទំនងរវាងថវិកាខេត្ត-ក្រុង និង ថវិកាស្រុក ខណ្ឌ " លេខ ៤៥៧ "

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលមានការពាក់ព័ន្ធ នឹងចំណូល ចំណាយថវិកាស្រុក ។ គណនីនេះមានការពាក់ព័ន្ធជាមួយគណនីប្រាក់បញ្ញើរបស់ថវិកាខេត្ត-ក្រុង នៅរតនាគារខេត្ត ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ ស្មើនឹងចំណូលថវិការបស់ស្រុក ខ័ណ្ឌដែលពាក់ពន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

- កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិការបស់ស្រុក ខ័ណ្ឌដែលពាក់ពន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិការបស់ស្រុកដែលពាក់ពន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

- កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណូលថវិការបស់ស្រុកដែលពាក់ពន្ធគណនីប្រាក់បញ្ញើខេត្ត-ក្រុង

សមតុល្យ : អសមតុល្យ ។

ចំណាំ : គណនីលេខ ៤៥៧ ជាគណនីចំលង និង បង្ហាញអំពីទំនាក់ទំនងជាមួយគណនីប្រាក់បញ្ញើថវិកាខេត្ត-ក្រុង ដែល ប្រើរួមគ្នា រវាង ខេត្ត-ក្រុង និង ស្រុក ខ័ណ្ឌ ។

២៨-គណនី ប្រាក់តំកល់ធានាលើទីផ្សារសាធារណៈ " លេខ ៤៦២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការបាន បង់សំរាប់ដំកល់ធានាការពេញថ្លៃលើការផ្គត់ផ្គង់សំភារៈសេវាកម្ម ដោយយោងតាមកិច្ចសន្យា ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានសងទៅអ្នកដែលបានបង់ប្រាក់

- កត់ត្រាចំនួនទឹកប្រាក់តំកល់ ធានាដែលបានផ្ទេរចូលថវិកា ខេត្ត-ក្រុង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តំកល់ធានា ដែលត្រូវសង ។

ចំណាំ : - គណនីនេះត្រូវចែកទៅជាអនុគណនីលំអិតសំរាប់តាមដានទៅតាមអ្នកបានបង់ប្រាក់

- នៅពេលដកប្រាក់តំកល់ធានាទៅវិញ ខេត្ត-ក្រុង ត្រូវចេញលិខិតបញ្ជាក់មក រតនាគារដើម្បីបើកផ្តល់ ប្រាក់ ។

២៩-គណនី ឥណទាយិក ឥណទាយីផ្សេង ៗ " លេខ ៤៦៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវផ្ទេរទៅគណនីសកម្ម ឬ អកម្មផ្សេងទៀត ឬត្រូវធ្វើនិយ័តកម្ម ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវដោះស្រាយ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានដោះស្រាយ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវដោះស្រាយ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានដោះស្រាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃផ្នែកសកម្មដែលរង់ចាំការដោះស្រាយ

ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃផ្នែកអកម្មដែលរង់ចាំការដោះស្រាយ ។

<u>ចំណាំ</u> : គណនីនេះត្រូវចែកទៅជាអនុគណនី សំរាប់តាមដានចំណូលត្រូវដោះស្រាយ និងសំរាប់ចំណាយត្រូវដោះស្រាយ ។

៣០-គណនី ចំណូលផ្សេងៗរង់ដោះស្រាយ " លេខ ៤៧០ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអកម្មផ្សេងទៀត ។ គណនីលេខ ៤៧០ ជាគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការដោះស្រាយ ។

<u>ចំណាំ</u> : គណនីលេខ ៤៧០ ត្រូវចែកទៅជាអនុគណនីទៅតាមប្រភពចំណូលនីមួយៗ ។

៣១-គណនី ចំណាយផ្សេងៗ រង់ដោះស្រាយ " លេខ ៤៧២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយផ្សេងៗ ដែលត្រូវធ្វើនិយ័ត្តកម្ម។ គណនីលេខ ៤៧២ ជាគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ ។

<u>ចំណាំ</u> : គណនីលេខ ៤៧២ ត្រូវចែកជាអនុគណនីទៅតាមមុខសញ្ញាចំណាយនីមួយៗ ។

៣២_គណនី រដ្ឋទេយ្យករចំណូល " លេខ ៤៧៧ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋទេយ្យករ ចំណូល ខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលបានផ្ទេរចូលថវិកាខេត្ត-ក្រុង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលរដ្ឋទេយ្យករបានបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលពុំទាន់បានផ្ទេរចូលថវិកាខេត្ត-ក្រុង ។

__ចំណាំ__ : គណនីលេខ ៤៧៧ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៣៣_គណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន " លេខ ៤៨២ " :

គណនីនេះបើកនៅរតនាគាខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល មិនមែនសារពើពន្ធដែល ត្រូវទារពីអាជីវករ ។ គណនីលេខ ៤៨២ កត់ត្រាបដិភាគ ជាមួយគណនីអតិថិជន (លេខ ៤១៣) ដោយយោងតាម របាយការណ៍ កិច្ចសន្យា របស់ខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលប្រមូលបាន ដោយបដិភាគនឹងគណនីអតិថិជន

- កត់ត្រាចំនួនទឹកប្រាក់មិនមែនពន្ធដែលបានជំរះដោយបន្ធូរបន្ថយ ឬ លប់ចោល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មិនមែនពន្ធដែលត្រូវប្រមូល ដោយបដិភាគនឹងគណនី អតិថិជន (លេខ ៤១៣)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មិនមែនពន្ធដែលត្រូវប្រមូល ។

__ចំណាំ__ : ការកត់ត្រាខាងឥណទានគណនី លេខ ៤៨២ ទន្ទឹមនឹងលេខនាកត់ត្រាចំណូលពិតប្រាកដដែលប្រមូលបាន (ឥណពន្ធ គណនី ហិរញ្ញវត្ថុ និង ឥណទាន គណនី ចំណូលថវិកា) ។

៣៤_គណនី ប្រាក់បញ្ញើនៅរតនាគារ ខេត្ត-ក្រុង " លេខ ៥១៥ " :

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយ មូលនិធិដែល សាលាខេត្ត-ក្រុង និង ស្រុក ខ័ណ្ឌផ្ញើនៅរតនាគារ ។

ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះគឺមានទំនាក់ទំនងជាមួយ

នឹង ចំណូល ចំណាយថវិកា ប្រាក់តំកល់ធានាលើទីផ្សារសាធារណៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់ ជាចំណូលថវិកា ឬជាចំណូលសាច់ប្រាក់ផ្សេងៗ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកជាចំណាយថវិកា ឬជាចំណាយសាច់ប្រាក់ផ្សេងៗ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនមូលនិធិរបស់ខេត្ត-ក្រុង កំពុងមាននៅរតនាគារ ។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី សំរាប់ថវិកាខេត្ត ថវិកាក្រុងសំរាប់អគ្គីសនី និងថវិកាក្រុងសំរាប់ទឹក

- គណនីលេខ ៥១៥ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាស នឹងគណនីប្រាក់បញ្ញើរបស់ខេត្ត-ក្រុង (លេខ ៤៤២) នៃប្លង់គណនេយ្យរដ្ឋ ។

៣៥-គណនី បុរេប្រទានពីរតនាគារ "លេខ ៥១៩" :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែល ខេត្ត-ក្រុង បានទទួលពីរតនាគារ យោងតាមការសំរេចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬរតនាគារជាតិ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលខេត្ត-ក្រុងបានទូទាត់ ដោយកាត់ពីគណនីប្រាក់បញ្ញើនៅរតនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលខេត្ត-ក្រុង បានបុរេប្រទានពីរតនាគារដោយបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើនៅរតនាគារ

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់បុរេប្រទានដែល ខេត្ត-ក្រុង ពុំទាន់បានទូទាត់ ។

៣៦-គណនី រដ្ឋទេយ្យករបុរេប្រទាន "លេខ ៥៤៣" :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលខេត្ត-ក្រុងបានទទួលពីរតនាគារតាមរយៈរដ្ឋទេយ្យករបុរេប្រទាន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនប្រាក់ដែលបានបើកផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទាន ខេត្ត-ក្រុង

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាអាណត្តិបើកប្រាក់

- កត់ត្រាចំនួនប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានបង់ចូលរតនាគារ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ ។

ចំណាំ : -ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន គឺធ្វើនៅក្រៅកិច្ចបញ្ជីការគណនេយ្យ

-គណនី លេខ ៥៤៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៣៧-គណនី និញសំភារៈផ្គត់ផ្គង់ថែទាំ " លេខ ៦០១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការ

ទិញសំភារៈផ្គត់ផ្គង់ ថែទាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

__ចំណាំ__ : គណនីលេខ ៦០១ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញសំភារៈផ្គត់ផ្គង់សំអាត និងអនាម័យ ទិញសំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ ទិញសំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ផ្លូវលំ ស្ពាន និង លូ ទិញសំភារៈផ្គត់ផ្គង់ថែទាំសំភារៈ ឧបករណ៍ និងសំរាប់ទិញ ប្រេងឥន្ធនៈ និងប្រេងរំអិល ។

៣៨-គណនី ទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល " លេខ ៦០២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ខេត្ត-ក្រុង លើការទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

__ចំណាំ__ : គណនីលេខ ៦០២ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញសំភារៈការិយាល័យ និង ការបោះពុម្ព ទិញសៀវភៅមើល និងឯកសារ និង សំរាប់ទិញសំភារៈផ្សេងៗ ។

៣៩-គណនី ទិញស្បៀងអាហារ " លេខ ៦០៣ " :

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនទឹកប្រាក់ចំណាយថវិកា ខេត្ត-ក្រុង លើការទិញស្បៀងអាហារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃ

ការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៣ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញស្បៀង ។

៤០_គណនី ទិញសំលៀកបំពាក់ និងការតុបតែង " លេខ ៦០៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទិញសំលៀកបំពាក់ និង ការតុបតែងលំអ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៤ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញឯកសណ្ឋាន ទិញសំលៀកបំពាក់ការពារសុវត្ថិភាព ទិញមេដាយ (គ្រឿងឥស្សរយស) និងសំរាប់ទិញសំលៀកបំពាក់ការតុបតែងផ្សេងៗទៀត ។

៤១_គណនី ទិញសំភារៈតូចតាច សង្ហារឹម និង សំភារៈបរិក្ខារ " លេខ ៦០៥ " :

គណនីនេះ បើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទិញសំភារៈ សង្ហារឹម និង សំភារៈបរិក្ខារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៥ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញសំភារៈនិងបរិក្ខារ ទិញសង្ហារឹម ទិញសំភារៈប្រើប្រាស់ និងសំរាប់ទិញសំភារៈផ្សេងៗទៀត ។

៤២_គណនី ទិញថាមពល និង ទឹក " លេខ ៦០៦ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់ការប្រើប្រាស់ថាមពល និង ការប្រើប្រាស់ទឹក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាកបានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦០៦ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើអគ្គីសនី ចំណាយលើថ្លៃទឹក និងសំរាប់ចំណាយលើការទិញថាមពលផ្សេងៗទៀត ។

៤៣-គណនី ទិញសំភារៈផ្គត់ផ្គង់ផ្សេង ៗ " លេខ ៦០៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទិញសំភារៈផ្គត់ផ្គង់ផ្សេងៗ ទៀត ដែលពុំបានរៀបរាប់ខាងលើ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៤៤-គណនី ចំណាយលើកិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស " លេខ ៦១១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ខេត្ត-ក្រុង លើការទូទាត់ជូនទៅសហគ្រាស ក្រុមហ៊ុន ឬ អាជីវករដែលបានផ្តល់សេវាកម្មដល់ខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៤៥-គណនី ចំណាយលើការជួលមធ្យោបាយដឹកជញ្ជូន " លេខ ៦១២ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្អូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៤៦_គណនី ចំណាយលើថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) " លេខ ៦១៣ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់ថ្លៃឈ្នួលទីតាំង ស្នាក់ការរដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្អូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៤៧_គណនី សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក "លេខ ៦១៤ ":

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការបណ្តុះបណ្តាលបុគ្គលិក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្អូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៤៨_គណនី ចំណាយលើការថែទាំ និង ជួសជុល " លេខ ៦១៥ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការថែទាំ និងជួសជុល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹក ប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦១៥ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើការថែទាំដីធ្លី សួនច្បារ រៀបជាផ្លូវ ការថែទាំ ទីផ្សារនិងសត្តឃាតដ្ឋាន និងអាគារសាធារណៈ ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រព័ន្ធលូ ការថែទាំបណ្តាញផ្សេងៗ ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន ការថែទាំនិងជួសជុលសំភារៈការិយាល័យសំភារៈពិតមានវិទ្យា និងទូរគមនាគមន៍ និងសំរាប់ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស ។

៤៩_គណនី សោហ៊ុយធានារ៉ាប់រង " លេខ ៦១៦ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើការបង់សោហ៊ុយធានារ៉ាប់រងផ្សេង ៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៥០_គណនី សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ " លេខ ៦១៧ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង សោហ៊ុយនៃការប្រើប្រាស់សិទ្ធ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦១៧ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើសោហ៊ុយ សិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសំរាប់សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ ។

៥១_គណនី សោហ៊ុយដឹកជញ្ជូន " លេខ ៦១៨ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើសោហ៊ុយដឹកជញ្ជូនសំភារៈ និងទំនិញ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦១៨ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើថ្លៃដឹកជញ្ជូនសំភារៈនិងទំនិញ (ដឹកបញ្ជើ ប្រៃសណីយ៍ជាដើម) ។

៥២_គណនី ចំណាយលើបុគ្គលិកខាងក្រៅ " លេខ ៦២១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់ប្រាក់បំណាច់ លាភការ របស់បុគ្គលិកក្រៅពីបុគ្គលិកក្របខ័ណ្ឌខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦២១ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើភ្នាក់ងារជាតិជាប់កិច្ចសន្យា សំរាប់ភ្នាក់ងារបរទេសជាប់កិច្ចសន្យា និងសំរាប់បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ ។

៥៣_គណនី ចំណាយលើទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ " លេខ ៦២២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦២២ ត្រូវបែងចែកទៅជាអនុគណនី សំរាប់ចំណាយសោហ៊ុយទទួលភ្ញៀវជាតិ សោហ៊ុយទទួលភ្ញៀវបរទេស ប្រជុំសិក្ខាសាលានិង សន្និសីទ សោហ៊ុយពិធីបុណ្យ ការទិញវត្ថុអនុស្សាវរីយ៍ក្នុងនិងក្រៅប្រទេស សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុង និង ក្រៅប្រទេស និងសំរាប់ការឃោសនា និង ផ្សព្វផ្សាយព័ត៌មានសាធារណៈ ។

៥៤-គណនី សោហ៊ុយថ្លៃសារព័ត៌មាន និង ឯកសារ " លេខ ៦២៣ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់ថ្លៃសារព័តមាន និង ទិញឯកសារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ ។

៥៥-គណនី ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស " លេខ ៦២៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្នុងប្រទេស ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការីយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦២៤ត្រូវបែងចែកទៅជាអនុគណនី សំរាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និង សំរាប់សោហ៊ុយស្នាក់នៅ ។

៥៦-គណនី ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស " លេខ ៦២៥ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់សោហ៊ុយ ធ្វើដំណើរបេសកកម្ម និង សោហ៊ុយស្នាក់នៅក្រៅប្រទេស ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញអំពីចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦២៥ ត្រូវចែកទៅជាអនុគណនី សំរាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសំរាប់សោហ៊ុយស្នាក់នៅ ។

៥៧-គណនី សោហ៊ុយទូរគមនាគមន៍ ទូរសព្ទ តេឡិច ទូរសារប្រៃសណីយ៍ "លេខ ៦២៦" :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់សេវាទូរគមនាគមន៍ ទូរស័ព្ទ ទូរសារប្រៃសណីយ៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញអំពីចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦២៦ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយសោហ៊ុយប្រៃសណីយ៍ និងសំរាប់ចំណាយសោហ៊ុយទូរគមនាគមន៍ ។

៥៨-គណនី សោហ៊ុយធនាគារ " លេខ ៦២៧ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើសេវាធនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៥៩. គណនី សោហ៊ុយផ្សេងៗ " លេខ ៦២៨ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការទូទាត់សោហ៊ុយផ្សេងៗ ទៀត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦០. គណនី ចំណាយលើលតាប័ត្រ " លេខ ៦៣១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការបង់ពន្ធលតាប័ត្រ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៦១. គណនី ចំណាយលើលាភការ និងប្រាក់បំណាច់ នៃអំណាចសាធារណៈ" លេខ ៦៤១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើលាភការ និង ប្រាក់បំណាច់នៃអំណាចសាធារណៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៤១ ត្រូវចែកទៅជាអនុគណនី សំរាប់ប្រាក់បំណាច់អភិបាលខេត្ត-ក្រុង ប្រាក់បំណាច់អភិបាលរងខេត្ត-ក្រុង លាភការទីប្រឹក្សា និង លាភការបេសកជន ។

៦២_អនុគណនី ការសង និងការបង្វិលទិញនូវលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ " លេខ ៦៤១៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកា ដែលបានមកពីបង្វិលសងមកថវិកាខេត្ត-ក្រុង វិញនូវលាភការ និង ប្រាក់បំណាច់ (ជាសំណេះចំណាយ) នៃអំណាចសាធារណៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងមកថវិកាវិញ ដែលបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានទទួលពីការសង និង ការបង្វិលទិញនូវលាភការនិងប្រាក់បំណាច់នៃអំណាចសាធារណៈ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងដែលបានទទួល ដែលពុំទាន់បានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកា ។

__ចំណាំ__ : - គណនីលេខ ៦៤១៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់ប្រាក់ចំណូលថវិកាពីការបង្វិលសងវិញនីមួយៗ ដោយយកលេខចុងក្រោយនៃអនុគណនីចំណាយថវិកាពាក់ព័ន្ធបន្ថែមពីក្រោយលេខអនុគណនីការបង្វិលសងវិញនេះ ។

- គណនីលេខ ៦៤១៩ ត្រូវផ្ទេរទៅកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធមុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ ។

៦៣_គណនី ចំណាយលើលាភការនិងប្រាក់បំណាច់បុគ្គលិកក្រុមខ័ណ្ឌអចិន្ត្រៃយ៍"លេខ ៦៤២ ":

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើលាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

__ចំណាំ__ : គណនីលេខ ៦៤២ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងបន្ថែម ប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ទទួលខុសត្រូវ និងប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព ។

៦៤_អនុគណនី ការសង និង ការបង្វិលទិញនូវប្រាក់បំណាច់បុគ្គលិកក្រុមខណ្ឌអចិន្ត្រៃយ៍ " លេខ ៦៤២៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានមកពីការសង និង ការបង្វិលវិញនូវប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ ចូលជាចំណូលថវិកាខេត្ត-ក្រុង វិញ (ជាសំណេះចំណាយ) ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងមកថវិកាវិញ ដែលបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកា ដែលបានពីការសង និងការបង្វិលវិញនូវប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ការសង និងការបង្វិលវិញដែលបានទទួលបូកបន្តដែលពុំទាន់បានផ្ទេរកាត់កងជាមួយគណនីចំនាយថវិកាពាក់ព័ន្ធ ។

ចំណាំ : - គណនីលេខ ៦៤២៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់ប្រាក់ចំណូលថវិកាពីការបង្វិលសងវិញនីមួយៗ ដោយយកលេខចុងក្រោយនៃអនុគណនីចំណាយថវិកាពាក់ព័ន្ធបន្ថែមពីក្រោយលេខអនុគណនីការបង្វិលសងវិញនេះ ។

- គណនីលេខ ៦៤២៩ ត្រូវផ្ទេរទៅកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធមុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ ។

៦៥_គណនី ចំណាយលើរង្វាន់ និង ប្រាក់បំណាច់ផ្សេងៗ ទៀត " លេខ ៦៤៣ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើរង្វាន់ និង ប្រាក់បំណាច់ផ្សេងៗទៀត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៤៣ ត្រូវចែកទៅជាអនុគណនីសំរាប់កន្សោមអាទិភាព ប្រាក់បំណាច់សំរាប់ប្រឡង ប្រឡងប្រជែង រង្វាន់ ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ និងប្រាក់បំណាច់ផ្សេងៗទៀត ។

៦៦. អនុគណនី ការសងនិងការបង្វិលវិញនូវរង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត " លេខ ៦៤៣៩ " :

អនុគណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត ដែលបានបង្វិលសងមកជាចំណូលថវិកាខេត្ត-ក្រុងវិញ (ជាសំណេះចំណាយ) ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានបង្វិលសងមកវិញ ហើយផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការបង្វិលសងវិញ នូវប្រាក់រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងដែលបានទទួល តែពុំទាន់បានកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ ។

ចំណាំ : - គណនីលេខ ៦៤៣៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់ប្រាក់ចំណូលថវិកាពីការបង្វិលសងវិញនីមួយៗ ដោយយកលេខចុងក្រោយនៃអនុគណនីចំណាយថវិកាពាក់ព័ន្ធបន្ថែមពីក្រោយលេខអនុគណនីការបង្វិលសងវិញនេះ ។

- គណនីលេខ ៦៤៣៩ ត្រូវផ្ទេរទៅកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធមុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ ។

៦៧. គណនី ចំណាយលើលាភការ និង ប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត " លេខ ៦៤៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ខេត្ត-ក្រុង លើលាភការ និង ប្រាក់បំណាច់ បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៤៤ ត្រូវចែកទៅជាអនុគណនីសំរាប់បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត ។

៦៨.អនុគណនី ការសង និងការបង្វិលវិញនូវលាភការ និងប្រាក់បំណាច់បុគ្គលិកអណ្តែត " លេខ ៦៤៤៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនប្រាក់លាភការ ប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត ដែលបានបង្វិលសងមកជាចំណូលថវិកាខេត្ត-ក្រុងវិញ (ជាសំណេះចំណាយ) ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងមកថវិកាវិញ ដែលបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងវិញនូវលាភការ និងប្រាក់បំណាច់បុគ្គលិកអណ្តែត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងដែលបានទទួលបូកបន្ត ហើយពុំទាន់បានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ ។

ចំណាំ : - គណនីលេខ ៦៤៤៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់ប្រាក់ចំណូលថវិកាពីការបង្វិលសងវិញនីមួយៗ ដោយយកលេខចុងក្រោយនៃអនុគណនីចំណាយថវិកាពាក់ព័ន្ធបន្ថែមពីក្រោយលេខអនុគណនីការបង្វិលសងវិញនេះ ។

- គណនីលេខ ៦៤៤៩ ត្រូវផ្ទេរទៅកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធមុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ ។

៦៩.គណនី ចំណាយលើប្រាក់វិភាជន៍សង្គម " លេខ ៦៤៥ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើប្រាក់វិភាជន៍សង្គម ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៤៥ ត្រូវចែកជាអនុគណនី សំរាប់ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន មរណភាព ឧបត្ថម្ភនិវត្តជន ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ គ្រោះថ្នាក់ការងារ និងទុព្វលភាព ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ និងសំរាប់ប្រាក់វិភាជន៍សង្គមផ្សេងៗទៀត ។

៧០_អនុគណនី ការសង និងការបង្វិលទិញនូវប្រាក់វិភាជន៍សង្គម " លេខ ៦៤៥៩ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនប្រាក់វិភាជន៍សង្គមដែលបានបង្វិលសងមកជាចំណូលថវិកាខេត្ត-ក្រុងវិញ (ជាសំណោះចំណាយ) ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងមកជាចំណូលថវិកាវិញ ហើយបានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីការបង្វិលសងនូវប្រាក់វិភាជន៍សង្គម

សមតុល្យ: ឥណទាយី បង្ហាញចំនួនទឹកប្រាក់បង្វិលសងដែលបានទទួលបូកបន្ត តែពុំទាន់បានផ្ទេរកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធ ។

<u>**ចំណាំ**</u> : - គណនីលេខ ៦៤៥៩ ត្រូវចែកទៅជាអនុគណនីបន្ត សំរាប់ប្រាក់ចំណូលថវិកាពីការបង្វិលសងវិញនីមួយៗ ដោយយកលេខចុងក្រោយនៃអនុគណនីចំណាយថវិកាពាក់ព័ន្ធបន្ថែមពីក្រោយលេខអនុគណនីការបង្វិលសងវិញនេះ ។

- គណនីលេខ ៦៤៥៩ ត្រូវផ្ទេរទៅកាត់កងជាមួយគណនីចំណាយថវិកាពាក់ព័ន្ធមុនការគណនាលទ្ធផលនៃការិយបរិច្ឆេទ ។

៧១_គណនី ចំណាយឧបត្ថម្ភធនដល់រដ្ឋបាលដែនដី " លេខ ៦៥១ ":

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើការផ្តល់ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

<u>**ចំណាំ**</u> : គណ នីលេខ ៦៥១ ត្រូវចែកជាអនុគណនីសំរាប់ឧបត្ថម្ភធនដល់ស្រុក ខ័ណ្ឌ ឧបត្ថម្ភដល់ ឃុំ សង្កាត់ និងសំរាប់ឧបត្ថម្ភដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។

៧២_គណនី ចំណាយលើជំនួយសង្គម និង ប្រាក់វិភាជន៍ " លេខ ៦៥២ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើការជួយឧបត្ថម្ភធនដល់កិច្ចការសង្គម និង ប្រាក់វិភាជន៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាប្លុកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៥២ ត្រូវបែងចែកជាអនុគណនី សំរាប់ជួយប្រជាជនក្រីក្រសំរាកពេទ្យ ជួយជនរងគ្រោះដោយធម្មជាតិ និងសំរាប់ចំណាយសង្គមផ្សេងៗទៀត ។

៧៣_គណនី ចំណាយឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គម និងវប្បធម៌ "លេខ ៦៥៣ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើការផ្តល់ឧបត្ថម្ភកធនដល់អង្គភាព មានលក្ខណៈសង្គម និង វប្បធម៌ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាប្លុកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៦៥៣ ត្រូវបែងចែកជាអនុគណនី សំរាប់ឧបត្ថម្ភមណ្ឌលកុមារកំព្រា ឧបត្ថម្ភសហគមន៍ កីឡា និង វប្បធម៌ និងសំរាប់ឧបត្ថម្ភកាកបាទក្រហម ។

៧៤_គណនី ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន " លេខ ៦៧១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា ខេត្ត-ក្រុង លើ ឥណទេយ្យ ឬ ចំណាយផ្សេងៗ ដែលបានជំរះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ: ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្លុកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

៧៥_គណនី តំលៃគណនេយ្យ នៃចំណែកសកម្មបានលក់ (តំលៃនៅសល់)" លេខ ៦៧៥ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុងលើ តំលៃ

គណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់)។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៦-គណនី ទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី " លេខ ៦៨១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចាត់ជាចំណាយថវិកាខេត្ត-ក្រុង លើទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់វិលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៧-គណនី ទាយជ្ជទានអោយដល់វិលស់អចលកម្មរូបី " លេខ ៦៨២ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាខេត្ត-ក្រុង លើទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់វិលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

៧៨-គណនី ពន្ធលើបេតិកភ័ណ្ឌ " លេខ ៧០១ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ថវិកាដែលបានមកពីប្រាក់ពន្ធលើបេតិកភ័ណ្ឌនានា ។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានបន្ថយ ឬ ជំរះ

- កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធបេតិកភ័ណ្ឌដែលប្រមូលបាន និងដែលត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិការដ្ឋបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនី លទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៧០១ ត្រូវចែកទៅជាអនុគណនី សំរាប់ពន្ធប្រថាប់ត្រា - ពន្ធផ្ទេរមរតករវាងអ្នកនៅរស់ ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរសិទ្ធពីអ្នកស្លាប់ និងសំរាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

៧៩-គណនី ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ "លេខ ៧០២" :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាខេត្ត-ក្រុង ដែលបានមកពីពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ ដែលប្រមូលបាន និងដែលត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៧០២ ត្រូវចែកទៅជាអនុគណនី សំរាប់អាករបំភ្លឺសាធារណៈ ។

៨០-គណនី ពន្ធលើសេវាដែលបានកំណត់ " លេខ ៧០៣ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ថវិកាខេត្ត-ក្រុង ដែលបានមកពីពន្ធលើសេវាដែលបានកំណត់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធលើសេវាដែលបានកំណត់ដែលប្រមូលបាន និង ដែលត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៧០៣ ត្រូវចែកទៅជាអនុគណនី សំរាប់អាករលើការស្នាក់នៅ និង សំរាប់ពន្ធសត្តឃាត ។

៨១_គណនី ចំណូលពីអាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាព " លេខ ៧០៤ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ថវិកាខេត្ត-ក្រុងដែលបានមកពីអាករលើសេវាដែលបានកំណត់ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីអាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាពដែលប្រមូលបាន និង ដែលត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិការដ្ឋបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>**ចំណាំ**</u> : គណនីលេខ ៧០៤ ត្រូវចែកទៅជាអនុគណនី សំរាប់ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានយន្តគ្រប់ប្រភេទ ពន្ធលើការផ្គត់ផ្គង់អគ្គីសនីរបស់សហគ្រាសឯកជនតាមខេត្ត-ក្រុង ។

៨២_គណនី ផលនៃការជួលដីធ្លី " លេខ ៧២១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាខេត្ត-ក្រុងដែលបានមកពីផលពីការជួលដីធ្លី ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីការជួលដីធ្លីដែលប្រមូលបាន និង ដែលត្រូវប្រមូល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>**ចំណាំ**</u> : គណនីលេខ ៧២១ ត្រូវចែកទៅជាអនុគណនី សំរាប់សម្បទានពីរ៉ែ ការជួលកន្លែងលក់ដូរក្នុងទីផ្សារ ចំណូលពីចំណតរថយន្ត និងសំរាប់ចំណូលពីចំណតជលយាន ។

៨៣_គណនី ផលពីសហគ្រាសសាធារណៈរដ្ឋបាល និងសេវាទ្រព្យសម្បត្តិ " លេខ ៧៣១ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាខេត្ត-ក្រុងដែលបានពីផលសហគ្រាសសាធារណៈរដ្ឋបាល និង សេវាទ្រព្យសម្បត្តិ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីសហគ្រាសសាធារណៈ រដ្ឋបាល និង សេវាទ្រព្យសម្បត្តិដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្លុកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

៨៤_គណនី ផលពីការគ្រប់គ្រងរដ្ឋបាល" លេខ ៧៣២ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាខេត្ត-ក្រុងដែលបានពីការគ្រប់គ្រងរដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីកំរៃរដ្ឋបាល និងការអនុញ្ញាតិរដ្ឋបាលដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្លុកបន្ត ហើយពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ៧៣២ ត្រូវចែកទៅជាអនុគណនី សំរាប់សេវាសុរិយោដី សេវាសំណង់ ចំណូលសំរាប់ទំរង់ការរដ្ឋបាល ចំណូលពីការអនុញ្ញាត្តិរដ្ឋបាល និងសំរាប់ចំណូលរដ្ឋបាលផ្សេងៗទៀត ។

៨៥_គណនី ផលពីការជួលទ្រព្យសម្បត្តិអចលតៈ" លេខ ៧៣៣ " :

គណនីនេះ បើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រចំនួនទឹកប្រាក់ចំណូលថវិកាខេត្ត-ក្រុងដែលបានមកពីប្រាក់ពីការជួលទ្រព្យសម្បត្តិជាអចលកម្មនានា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីថ្លៃឈ្នួលទ្រព្យសម្បត្តិអចល័តដែលប្រមូលបាន និងដែលត្រូវប្រមូល

